ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

## លិខិតអំពាវនាវ

ដើម្បីចូលរួមអបអរសាទរការប្រារព្ធខួបលើកទី១៦០ ទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ "រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម" សំដៅលើកកម្ពស់ទឹកចិត្តមនុស្សធម៌ ក្នុងនាមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តក្រចេះ ខ្ញុំសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងអស់លោក លោកស្រី ជាមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ និងសប្បុរសជនទាំងអស់មេត្តាជួយឧបត្ថម្ភគាំទ្រដោយសទ្ធាជ្រះថ្លា ក្នុងស្មារតីនៃវប្បធម៌ចែករំលែកដល់សាខាកាកបាទក្រហមកម្ពុជាខេត្តក្រចេះ ដើម្បីសាខានេះមានលទ្ធផលធ្វើសកម្មភាពមនុស្សធម៌របស់ខ្លួនបន្តទៅទៀតក្នុងការចូលរួមជួយសង្គ្រោះជនរងគ្រោះ និងជនងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ និងវិបត្តិនានានៅមូលដ្ឋាន។

ក្នុងគោលដៅខាងលើ កន្លងទៅ ក្រសួងមុខងារសាធារណៈបានចូលរួមឧបត្ថម្ភផ្ដល់រួចហើយនូវថវិកាចំនួន ៥.០០០ដុល្លារ (ប្រាំពាន់ដុល្លារអាមេរិក) ជូន **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា។

អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់មេត្តាចូលរួមផ្ដល់វិភាគទានជាបន្តទៀតជូនដល់សាខាកាកបាទក្រហមកម្ពុជាខេត្តក្រចេះ។

ថវិកាចូលរួមអាចផ្ដល់ដោយត្រង់ទៅសាខាកាកបាទក្រហមកម្ពុជាខេត្តក្រចេះ ឬតាមរយៈ **ឯកឧត្តម សយ រតនៈ** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ដែលមានគណនី ABA Bank៖ 077 666 658 "SOY ROTANARK" (ដុល្លារ)។

ខ្ញុំមានក្ដីសង្ឃឹមនិងមានជំនឿយ៉ាងមុតមាំលើស្មារតីចែករំលែកបរិច្ចាគធនធានថវិកាតាមទឹកចិត្តសប្បុរសរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់។

ខ្ញុំសូមប្រសិទ្ធពរបវរសួស្ដីជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសប្បុរសជនទាំងអស់មេត្តាជួបប្រទះតែនឹងសេចក្ដីសុខចម្រើនគ្រប់ប្រការ ព្រមទាំងសម្បូរបែបដោយ ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខ ពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

ថ្ងៃ សុក្រ ១៥កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**
**និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តក្រចេះ**

**ព្រុំ សុខា**